ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០៥៣ សហវ.

# សេចក្តីសម្រេច

## ស្តីពី

## ការតែងតាំង និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំនិង មន្ត្រីនៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សានីតិកម្ម

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ទៅជាអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ដំឡើងនាយកដ្ឋានសហប្រតិបត្តិការនិងគ្រប់គ្រងបំណុល ទៅជាអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល និងបង្កើតនាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ប្រកាសលេខ ១០៣៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញ ប្រកាសលេខ ៨៥៤ សហវ.ប្រក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ ប្រកាសលេខ ៨៥៥ សហវ.ប្រក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការតែងតាំងអនុប្រធានប្រចាំការក្រុមប្រឹក្សានីតិកម្ម និងសមាសភាពលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ១.-**

ត្រូវបានតែងតាំងមន្ត្រី តាមផ្នែកជំនាញ នៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម ដូចមានរាយនាមខាងក្រោម÷

ក. ផ្នែកចំណាយថវិកានិងគណនេយ្យ

| | |
|---|---|
| ១-លោក រស់ សុខណ៌ារុណ | ប្រធាន |
| ២-លោក ឈិត សុចន្ត្រា | សមាជិក |
| ៣-លោក សៀក មានិត | សមាជិក |
| ៤-កញ្ញា ឃី ស្រីស្រស់ | សមាជិក។ |

ខ. ផ្នែកចំណូលសារពើពន្ធ

| | |
|---|---|
| ១-លោក ដៀប ពិសិដ្ឋ | ប្រធាន |
| ២-លោក ឈន ចាន់ណា | សមាជិក |
| ៣- លោក ហ៊ែល ប៊ុនថាន | សមាជិក |
| ៤-លោក សុខ ច័ន្ទកិត្យា | សមាជិក។ |

គ. ផ្នែកទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ

| | |
|---|---|
| ១-លោក ណន សាមឌី | ប្រធាន |
| ២-កញ្ញា ឈឿង រចនី | សមាជិក។ |

ឃ. ផ្នែកហិរញ្ញវត្ថុឯកជន

| | |
|---|---|
| ១-កញ្ញា អំ វីណា | ប្រធាន |
| ២-លោក គៀន ប៊ុនធឿន | សមាជិក។ |

ង. ផ្នែកអភិបាលកិច្ច

| | |
|---|---|
| ១-កញ្ញា សរ សាគីនណា | ប្រធាន |
| ២-លោក សែម ប្រាក់ | សមាជិក |
| ៣-កញ្ញា ម៉ា គុជរចនា | សមាជិក |
| ៤-កញ្ញា សុខ ស្រីពៅ | សមាជិក។ |

ច. ផ្នែកព័ត៌មានវិទ្យានីតិកម្ម

| | |
|---|---|
| ១-លោក សួ សុភា | ប្រធាន |
| ២-លោក ហួត វ៉េងហួ | សមាជិក។ |

ឆ. ផ្នែកគាំទ្រទូទៅ

| | |
|---|---|
| ១- លោក អ៊ុក ឧត្តម | ប្រធាន |
| ២- កញ្ញា ខែម លក្ខណា | សមាជិក |
| ៣- លោកស្រី ចន ចាន់ណា | សមាជិក |
| ៤- លោកស្រី អ៊ិប ណាល័យ | សមាជិក |
| ៥- លោកស្រី ម៉ែន ម៉ាលី | សមាជិក |
| ៦- លោក ហ៊ួន សារ៉េត | សមាជិក។ |

**ប្រការ២.-**

ត្រូវបានកំណត់និងបែងចែកភារកិច្ច របស់ថ្នាក់ដឹកនាំលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម ដូចខាងក្រោម÷

- លោក ស៊ាង ផល្លា ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម ទទួលបន្ទុកដឹកនាំ និងគ្រប់គ្រងការងារទាំងអស់របស់លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម
- លោកស្រី លឹម ឈុនធី អនុប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម ទទួលបន្ទុកផ្នែកគាំទ្រទូទៅ
- លោក រស់ សុខណារុណ អនុប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម ទទួលបន្ទុកផ្នែកហិរញ្ញវត្ថុឯកជន, ផ្នែកចំណាយថវិកានិងគណនេយ្យ, និងផ្នែកអភិបាលកិច្ច
- លោក ណន សាមឌី អនុប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម ទទួលបន្ទុកផ្នែកទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ និងផ្នែកចំណូលសារពើពន្ធ។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ និងប្រការ២ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០១៦

អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## រចនាសម្ព័ន្ធដឹកនាំនៃលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម

